# មេរៀនទី៦៤៖ មិត្តភក្តិបួននាក់ជួយបុរសខ្វិន

[ម៉ាកុស ២៖១-១២]

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/QE4DVD6dFVw

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/VynZgET6-nk

**គោលបំណង៖** ព្រះយេស៊ូវគឺជាមិត្តសម្លាញ់របស់យើង

**ខគម្ពីរចងចាំ៖ យ៉ូហាន ១៥៖១៤** *"បើអ្នករាល់គ្នាធ្វើតាមសេចក្ដីដែលខ្ញុំបង្គាប់ នោះអ្នករាល់គ្នាជាពួកសំឡាញ់ខ្ញុំហើយ "*។

**ចំរៀង** ( *យូធូបលីង* )៖

១. ខ្ញុំមានមិត្តសម្លាញ់គឺព្រះយេស៊ូវ https://youtu.be/JccRviWgTsE

២. មានទន្លេជីវិត https://youtu.be/AP6fwLxUqK0

៣. ទ្រង់មិនដែលខាន https://youtu.be/uVqBqBENPi4

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «ស្វែងរកមិត្តរបស់អ្នក!»



១.សូមត្រៀមក្រដាស ៣ឈុត ដែលមានពណ៌ខុសៗគ្នា តែត្រូវមានសម្រាប់កុមារគ្រប់ៗគ្នា។ ហើយសូមបត់វាឲ្យជិត ដើម្បីកុំឲ្យកុមារមើលឃើញពណ៌នៅខាងក្នុង។

២.សូមឲ្យកុមារចាប់ក្រដាសមួយ ហើយកុំទាន់ឲ្យពួកគេបើកវាឲ្យសោះ។

៣.នៅពេលដែលកុមារគ្រប់គ្នាបានក្រដាសហើយ សូមឲ្យពួកគេបើកដំណាលគ្នា។ សូមពន្យល់កុមារថាពួកគេត្រូវស្វែងរកមិត្តភក្តិរបស់ពួកគេ គឺអ្នកណាដែលមានក្រដាសពណ៌ដូចគ្នាគឺជាមិត្តភក្តិរបស់ពួកគេ។

៤.ក្រុមណាដែលអាចស្វែងរកមិត្តភក្តិរបស់ពួកគេអស់ ហើយអង្គុយចុះបានមុនគេនោះគឺជាអ្នកឈ្នះ នៅក្នុងល្បែងនេះ។ សូមឲ្យកុមារអង្គុយក្នុងក្រុមរបស់ពួកគេនៅពេលថ្វាយបង្គំ ដើម្បីឲ្យយើងងាយស្រួលក្នុងការលេងល្បែងផ្សេងទៀតនៅពេលក្រោយ។

## ៤. ការណែនាំមេរៀន

គ្រូនាំកុមារទាំងអស់ឲ្យដើរតែជើងម្ខាង រួចសួរពួកគេថា តើការដើរជើងម្ខាងវាងាយស្រួលដែរឬទេ ។ តើប្អូននឹងដើរដោយរបៀបណាប្រសិនបើជើងទាំងពីររបស់ប្អូនមិនអាចប្រើការបាន? យើងច្បាស់ជាត្រូវការមិត្តភក្តិ ឬឪពុកម្តាយរបស់យើង ដើម្បីជួយយើង នោះទើបយើងអាចដើរបាន។ នៅថ្ងៃនេះយើងនឹងរៀនពីមិត្តភក្តិ ៤នាក់ ដែលបានជួយដល់បុរសខ្វិនម្នាក់។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅក្នុងទីក្រុងមួយដែលគេហៅថា កាពើណិម មនុស្សម្នាបានឮពីការយាងមករបស់ព្រះយេស៊ូវ ហើយទីនោះហើយគឺជាកន្លែងដែលពួកគេបានមកឮពីការបង្រៀន និងការអស្ចារ្យរបស់ព្រះយេស៊ូវ ។ នៅទីនោះមានបុរសបួននាក់ ដែលមានមិត្តភក្តិជាបុរសខ្វិន - គឺមានន័យថាគាត់មិនអាចដើរបាននោះទេ។ បុរសម្នាក់នោះ គឺត្រូវការមិត្តភក្តិដើម្បីជួយដល់គាត់។

មានមនុស្សម្នាជាច្រើនព្យាយាមចូលទៅមើលព្រះយេស៊ូវ វាគឺគ្មានផ្លូវណាសម្រាប់មិត្តភក្តិរបស់គាត់ អាចសែងគ្រែរបស់គាត់ចូលតាមទ្វារបាននោះទេ។ ពួកគេមិនទាំងអាចចូលទៅជិតព្រះយេស៊ូវបានផង។ ប៉ុន្តែបុរសទាំងបួនអ្នកនោះពិតជាត្រូវការឲ្យមិត្តភក្តិរបស់ពួកគេជួបជាមួយព្រះយេស៊ូវខ្លាំងណាស់។

នេះគឺជាអ្វីដែលពួកគេធ្វើ៖ ពួកគេបានដាក់ជណ្តើរឡើងទៅលើដំបូល។ ហើយនៅពេលដែលពួកគេ បានឡើងទៅលើដំបូលហើយ ពួកគេក៏ចាប់ផ្តើមរើដំបូល- រួចសម្រូតបុរសនោះពីលើដំបូលចុះមក! នៅពេលដែលមានចន្លោះធំល្មម បុរសទាំងបួនក៏ចាប់ផ្តើមសម្រូតខ្សែគ្រែបុរសនោះចុះក្រោម ឲ្យចំកន្លែងដែលព្រះយេស៊ូវកំពុងតែឈរបង្រៀន។

ព្រះយេស៊ូវបានមើលឃើញពីសេចក្តីជំនឿដែលមិត្តភក្តិទាំងនោះមាន។ ព្រះអង្គបានអង្គុយចុះ ហើយមានបន្ទូលទៅកាន់បុរសខ្វិននោះថា "មិត្តអើយ បាបរបស់ឯងបានអត់ទោសឲ្យឯងហើយ" ។

នៅទីនោះ មានអាចារ្យខ្លះអង្គុយរិះគិតក្នុងចិត្តថា **ម៉ាកុស ២៖៧** "ហេតុអ្វីបានជាមនុស្សនេះ ពោលពាក្យប្រមាថដល់ព្រះដូច្នេះ ក្រៅពីព្រះតែ១ តើមានអ្នកណាអាចនឹងអត់ទោសបាបបាន" ។

ព្រះយេស៊ូវបានជ្រាបដឹងពីអ្វីដែលពួកគេកំពុងគិត ហើយទ្រង់មានបន្ទូលថា **ម៉ាកុស ២៖៩-១១** "ដ្បិតដែលនិយាយនឹងមនុស្សស្លាប់ដៃស្លាប់ជើងនេះថា បាបឯងបានអត់ទោសឲ្យឯងហើយ ឬថា ឲ្យក្រោកឡើង យកគ្រែឯងដើរទៅ នោះតើពាក្យណាងាយថាជាង ប៉ុន្តែដើម្បីឲ្យអ្នករាល់គ្នាដឹងថា នៅផែនដីនេះ កូនមនុស្សមានអំណាចនឹងអត់ទោសបាបបាន (នោះទ្រង់មានព្រះបន្ទូល ទៅមនុស្សស្លាប់ដៃស្លាប់ជើងថា) អញប្រាប់ឲ្យឯងក្រោកឡើង យកគ្រែឯងដើរទៅផ្ទះទៅ" ។

តើអ្នកគិតថាមានរឿងអ្វីកើតឡើង? ព្រះគម្ពីរ **ម៉ាកុស ១៖១២** បាននិយាយថា "គាត់ក៏ក្រោកឡើងភ្លាម យកគ្រែចេញទៅ នៅមុខអ្នកទាំងអស់គ្នា បានជាគ្រប់គ្នាមានសេចក្តីអស្ចារ្យ ហើយពណ៌នាសរសើរដំកើងដល់ព្រះ ដោយពាក្យថា យើងមិនដែលឃើញយ៉ាងដូច្នេះឡើយ" ។

មនុស្សម្នាមានការភ្ញាក់ផ្អើលជាខ្លាំងនៅពេលដែលបានឃើញការនេះ! ព្រះយេស៊ូវបានប្រោសបុរសខ្វិនឲ្យជា ដោយសារទ្រង់ជាមិត្តភក្តិរបស់យើង! ព្រះយេស៊ូវមិនត្រឹមតែអ ត់ទោសបាបឲ្យយើងប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ ក៏បានមើលថែយើងដោយអំណាចចេស្តារបស់ទ្រង់ផងដែរ! នៅពេលដែលយើងមានមិត្តភក្តិដូចជាព្រះយេស៊ូវ នៅក្នុងជីវិតរបស់យើងគឺយើងនឹងមិនខ្លាចអ្វីទាំងអស់!

## ៦. សំនួរពិភាក្សា

១. ហេតុអ្វីបានជាបុរសទាំងបួនចង់ឲ្យមិត្តភក្តិខ្វិនពួកគេជួបព្រះយេស៊ូវ? *(ការប្រោសឲ្យជា)*

២. តើពួកគេបានធ្វើអ្វីខ្លះដើម្បីឲ្យមិត្តភក្តិរបស់ពួកគេបានជួបព្រះយេស៊ូវ? *(គឺពួកគេបានរើដំបូលផ្ទះហើយសម្រូតបុរសនោះចុះមកឲ្យចំពីមុខព្រះយេស៊ូវ)*

៣. តើព្រះយេស៊ូវបានធ្វើអ្វី មុនពេលដែលព្រះអង្គប្រោសជម្ងឺរបស់បុរសម្នាក់នោះ ?*(ព្រះអង្គបានឃើញពីសេចក្តីជំនឿរបស់បុរសម្នាក់នោះ ហើយទ្រង់បានអត់ទោស ចំពោះ អំពើបាបរបស់គាត់)*
៤. តើនរណាជាអ្នកដែលតែតែងតែមើលថែអ្នក និងជាមិត្តដ៏អស្ចារ្យរបស់អ្នក? *(ព្រះយេស៊ូវ)*

**៧. ល្បែងកំសាន្ត**



១. សូមឲ្យកុមារទាំងអស់ចូលទៅកាន់ក្រុមរបស់ពួកគេវិញដែលយើងបានលេងជាមួយគ្នាកាលពីល្បែងមុន ដែលមាន៣ក្រុម។
២. សូមឲ្យក្រុមនីមួយៗជ្រើសរើសកុមារម្នាក់ដើរតួជាមិត្តភក្តិខ្វិន។ ហើយអ្នកផ្សេងទៀតនៅក្នុងក្រុមត្រូវសែងកុមារនោះទៅកាន់ជ្រុងម្ខាងទៀតនៃបន្ទប់រៀន។
៣. ដំបូងពួកគេត្រូវសែងឲ្យដល់ចុងបន្ទប់រៀន ហើយគ្រូដើរតួជា "ព្រះយេ-ស៊ូវ" រួចក៏ទៅប៉ះកុមារ ដែលត្រូវគេសែងនោះហើយនិយាយថា "អ្នកត្រូវ បានប្រោសឲ្យជាហើយ" ។ ហើយក្រុមទាំងមូលត្រូវរត់ទៅកាន់ កន្លែងដើម វិញ ក្រុមណាដែលត្រឡប់ទៅកន្លែងដើមវិញហើយអង្គុយចុះបានមុនគេគឺជា ក្រុមដែលឈ្នះ។
៤. សូមឲ្យកុមារចងចាំថា បុរសពិការពិតជាត្រូវការនរណាម្នាក់ ដើម្បីជួយដល់គាត់ក្នុងការនាំគាត់ទៅជួបព្រះយេស៊ូវ។ គាត់ត្រូវការ មិត្តភក្តិរបស់គាត់ក្នុងការនាំគាត់ទៅ។ ហើយយើងក៏អាចជួយនាំមិត្តភក្តិរបស់យើងទៅឯព្រះយេស៊ូវបានដែរ។ យើងអាចប្រាប់មិត្តរបស់យើង អំពីព្រះយេស៊ូវ ហើយអញ្ជើញពួកគេឲ្យទៅ ព្រះវិហារជាមួយអ្នក។ ការអញ្ជើញមិត្តភក្តិទៅព្រះវិហារគឺដូចជាមិត្តភក្តិរបស់បុរសពិការដែលនាំ គាត់ទៅឯព្រះយេស៊ូវដែរ។

**៨. ខគម្ពីរចងចាំ**

**យ៉ូហាន ១៥៖១៤** *"បើអ្នករាល់គ្នាធ្វើតាមសេចក្តីដែលខ្ញុំបង្គាប់ នោះអ្នករាល់គ្នាជា ពួកសំឡាញ់ខ្ញុំហើយ "*។

**៩. ហាត្ថកម្ម**

សូមផាត់ពណ៌ មិត្តភក្តិទាំងបួនជួយបុរសខ្វិន

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
មិត្តភក្តិមានសារៈសំខាន់ណាស់ក្នុងជីវិត។ ការមានមិត្តល្អគឺអាចជួយយើងឆ្លងកាត់បញ្ហា ប៉ុន្តែការមានមិត្តអាក្រក់នាំឱ្យយើងមានបញ្ហា។ ហើយមិត្តភក្តិល្អបំផុតដែលអ្នកគួរមាននៅក្នុងជីវិតរបស់អ្នកគឺ ព្រះយេស៊ូវ។ ដោយសារព្រះយេស៊ូវស្រឡាញ់អ្នក ទ្រង់ក៏បានសុគតជំនួសអ្នកដែរ។ ព្រះអង្គមាន អំណាចខ្លាំងណាស់ ហើយទ្រង់ក៏តែងតែប្រើអំណាចរបស់ទ្រង់ ដើម្បីជួយអ្នកដូចជាវិធី ដែលព្រះអង្គបានជួយបុរសពិកាផងដែរ។ ថ្ងៃនេះ សូមអធិស្ឋាន ហើយទូលសុំឲ្យព្រះជួយអ្នកក្នុងការចងចាំថា ព្រះយេស៊ូវដ៏មានអំណាច គឺជាមិត្តល្អបំផុតរបស់អ្នក។

# មិត្តភក្តិបួននាក់ជួយបុរសខ្វិន



សូមសរសេរខគម្ពីរចងចាំៈ________________________________

________________________________________________

________________________________________________

________________________________________________